ទីស្ដីការក្រសួងយុត្តិធម៌

លេខ ១០៩២ ពគ. ខក្រ-៩៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>សារាចរណែនាំ</u>

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ផ្ញើចំពោះ</u>**

-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង

<u>សូមជ្រាប។</u>

**<u>កម្មវត្ថុ:</u>** អំពីការធ្វើបញ្ជីពិរុទ្ធជន និងទណ្ឌិត ។

**<u>យោង:</u>** លិខិតលេខ ៩៣៥ ពគ.ខក្រ-៩៥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៥ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបថា ក្រោយពីក្រសួងបានផ្ញើលិខិតដូចមានយោងខាងលើមកអយ្យការអមតុលាការគ្រប់ខេត្ត ក្រុង ក្រសួងបានពិនិត្យឃើញថា ការធ្វើបញ្ជីពិរុទ្ធជន អយ្យការអមតុលាការខេត្ត ក្រុង ពុំទាន់បានអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតណែនាំរបស់ក្រសួង ដូចមានក្នុងយោងនៅឡើយ ។ ម្យ៉ាងទៀតការឃុំខ្លួនពិរុទ្ធជនហួសថិរៈវេលាកំណត់នៃច្បាប់ គឺឃើញនៅតែមានបន្តទៀត ដែលជាលក្ខណៈខុសឆ្គងក្នុងការអនុវត្តច្បាប់ ។

ដើម្បីអនុវត្តច្បាប់អោយបានត្រឹមត្រូវ សូមលោកព្រះរាជអាជ្ញាយកចិត្តទុកដាក់អនុវត្តតាមបញ្ញត្តិមាត្រាទី២១ ចំនុច១ និងមាត្រាទី២២ ចំណុច ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឱ្យបានហ្មត់ចត់ ។ ដូច្នេះចាប់ពីខែនេះតទៅ សូមលោកធ្វើបញ្ជីពិរុទ្ធជនរៀងរាល់ខែផ្ញើទៅក្រសួងឱ្យបានទៀងទាត់ដោយបញ្ជាក់ថ្ងៃ ខែ ឆ្នាំ ឃុំខ្លួន និងបទល្មើសអោយបានច្បាស់លាស់ រីឯទណ្ឌិតមិនចាំបាច់ធ្វើបញ្ជីទេសូមលោករាយការណ៍តែចំនួន និងភេទ អាយុ ឱ្យបានច្បាស់លាស់បានហើយ ។

អាស្រ័យហេតុនេះ សូមលោកអនុវត្តតាមការណែនាំនេះ ឱ្យបានហ្មត់ចត់និងត្រឹមត្រូវបំផុត ដើម្បីកុំឱ្យមានការខុសឆ្គងក្នុងការរនុវត្តច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៥

**រដ្ឋមន្ត្រី**

**ចែម ស្កួន**